# ការសម្ភាសរបស់អ្នកមីង យ៉ាន់ លីន

**កៈ អ្នកសម្ភាសឈ្មោះ ម៉ៅ រតនា ខៈ អ្នកត្រូវគេសម្ភាសឈ្មោះ យ៉ាន់ លីន**
**គៈ ញ៉ែម សុគន្ធា**

កៈ ថ្ងៃនេះនាងខ្ញុំសូមថ្លែងអំណរគុណដល់ម៉ាក់ដែលបានឱ្យនាងខ្ញុំបានធ្វើបទសម្ភាសអំពីជីវប្រវត្តិរបស់ម៉ាក់ នាងខ្ញុំឈ្មោះម៉ៅ រតនា ជាអ្នកសម្ភាសហើយឈ្មោះពេញរបស់ម៉ាក់ឈ្មោះអី?

ខៈ ឈ្មោះពេញរបស់ម៉ាក់ឈ្មោះ យ៉ាន់ លីន។

កៈ ថ្ងៃនេះគឺខ្ញុំធ្វើការសម្ភាសនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៦ ការសម្ភាសត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យនៅសហរដ្ឋអាមេរិកឈ្មោះថា ប៊ី វ៉ាយ យូ សកលវិទ្យាល័យមានកម្មវិធីដើម្បីធ្វើការសម្ភាសអំពីជីវប្រវត្តិរបស់ម៉ាក់ ហើយប្រជាជនខ្មែរដើម្បីពេលអនាគតទៅមុខ កូនចៅរបស់ម៉ាក់ក៏ដូចជាមនុស្សជំនាន់ក្រោយបានដឹងពីជីវប្រវត្តិនិងដំណើររឿងនិងឆាកជីវិតរបស់ដូនតាម៉ាក់។តើម៉ាក់អនុញ្ញាតិឱ្យខ្ញុំបានដាក់ការសម្ភាសនេះចូលទៅក្នុងវេបសាយរបស់សកលវិទ្យាល័យបានដែរឬទេ?

ខៈ ចាសម៉ាក់យល់ព្រម។

កៈ ចាសដែលវេបសាយនេះឈ្មោះថា www.cambodiaoralhistory.byu.edu អញ្ចឹងនាងខ្ញុំនឹងចាប់ផ្តើមធ្វើការសម្ភាសម៉ាក់ សូមប្រាប់ឈ្មោះពេញរបស់ម៉ាក់ម្តងទៀត?

ខៈ ខ្ញុំឈ្មោះ យ៉ាន់ លីន។

កៈ តើមានឈ្មោះគេហៅក្រៅដែរឬទេ?

ខៈ ឈ្មោះហៅក្រៅគឺឈ្មោះជិន សុខលៀង។

កៈ តើម៉ាក់កើតនៅថ្ងៃខែឆ្នាំណា? ចាសអញ្ចឹងនាងខ្ញុំសូមអានថ្ងៃខែឆ្នាំកំណើតរបស់គាត់ជំនួសគាត់ ពីព្រោះគាត់អត់ចេះអក្សរ។គាត់កើតនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៦៧។ គាត់មានទីកន្លែងកំណើតនៅភូមិក្រពើហា ឃុំតាខ្មៅ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា។ តើឆ្នាំខ្មែរជាសត្វអី?

ខៈ សត្វស្វា ឆ្នាំវក។

កៈ តើមានបងប្អូនប្រុសស្រីប៉ុន្មាននាក់?

ខៈ បងប្អូនប្រុស២នាក់ បងប្រុស១ ប្អូនប្រុស១ ហើយស្រី៣។

កៈ តើម៉ាក់ជាកូនទីប៉ុន្មាន?

ខៈ ម៉ាក់ជាកូនទី៣។

កៈ តើឥឡូវមានបងប្អូននៅរស់ទាំងអស់ទេ?

ខៈ ម៉ាក់អត់ដឹងផងព្រោះកាលឆ្នាំ៧៥បែកគ្នាអស់ទៅ បែកអស់រលីងហើយអត់ដឹងថាគេរស់ឬក៏ស្លាប់ទេ ខ្ញុំទៅតែម្នាក់ឯង ខ្ញុំទៅជាមួយប៉ាខ្ញុំហើយប៉ាខ្ញុំក៏គាត់ស្លាប់បាត់ទៅហើយខ្ញុំក៏បានរស់នៅជាមួយម្ដាយចិញ្ចឹមណា។

កៈ អញ្ចឹងតើឪពុកម៉ាក់ឈ្មោះអីដែរ?

ខៈ គាត់ឈ្មោះ ជន ជិន។

កៈ ហើយទីកន្លែងកំណើតរបស់គាត់នៅណាដែរ? ចាសអញ្ចឹងខ្ញុំនឹងអាន ឪពុករបស់ម៉ាក់ឈ្មោះ សុខ ជីម។

ខៈ អត់ទេអាហ្នឹងប្ដីខ្ញុំ គាត់ចេះតែដាក់ៗទៅទេ ។

គៈ អញ្ចឹងឈ្មោះពិតគឺ សុខ ជីម អី?

ខៈ ការពិតគាត់ឈ្មោះ ជន ជិន។ ប្ដីខ្ញុំចេះតែដាក់ៗទៅទេ។

កៈ អញ្ចឹងថ្ងៃខែឆ្នាំកំណើតវិញគ្រាន់តែគាត់ចាំថាមានសញ្ជាតិខ្មែរ ហើយឆ្នាំ១៩២០ទីកន្លែងកំណើតនៅភូមិក្រពើហា ឃុំតាខ្មៅ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា។តើឆ្នាំខ្មែរគាត់ជាសត្វអីគេដែរ?

ខៈ ខ្ញុំនៅតូចណាស់ខ្ញុំអត់សួរចាំទេ។

កៈ តើគាត់ស្លាប់ឬក៏គាត់នៅរស់?

ខៈ គាត់ស្លាប់ហើយ។

កៈ ហើយចុះប្រសិនជាគាត់ស្លាប់នៅឆ្នាំណា?

ខៈ ស្លាប់កាលចូលទៅជំនាន់ ប៉ុល ពត តែម្ដង។ ស្លាប់បែកឆ្នាំ១៩៧៥កាលពីជំនាន់លុន ណុល

ចូលទៅអាពតទៅ ជម្លៀសចូលទៅក្នុងអាពត ហ្នឹងហាំ។ គ្រាន់តែស្លាប់នៅទីហ្នឹងតែម្តង។

ក៖ អញ្ចឹងឆ្នាំ១៩៧៥ តើម៉ាក់មានការចងចាំអ្វីខ្លះជាមួយនិងគាត់?

ខ៖ ចង់ចាំពីអីទៅ

ក៖ ដូចជាអនុស្សាវរីយ៍ជាមួយគាត់...

ខ៖ អូ... អនុស្សាវរីយ៍ដូចជាប៉ាខ្ញុំគាត់ធ្វើដូចជាទាហានមេបញ្ជាការធំនៅពេលថ្ងៃដែលគាត់សម្រាកពីការងារគាត់មកផ្ទះ មកដល់អញ្ចឹងទៅគាត់ទៅបង់សំណាញ់បានត្រីមួយយ៉ាងធំណាស់ ដល់ហើយទៅគាត់ក៏ហៅខ្ញុំ សុខលាង ខ្ញុំក៏ឆ្លើយថាសណោក...កូនឯងមើលណោកហើយខ្ញុំក៏ក្រឡេកមើលទៅឃើញត្រីធំណាស់ធំប៉ុនកូនង៉ែតណា រួចហើយខ្ញុំមានសប្បាយជាមួយនិងប៉ាខ្ញុំ។

គ៖ ចាសអាហ្នឹងពេលដែលមីងចាំជាងគេហ្នឹង។

ក៖ ម៉ាក់តើយាយឈ្មោះអីដែរ?

ខ៖ ម៉ែរបស់ខ្ញុំណោះ ខ្ញុំអត់ដឹងផង។

គ៖ ក្រែងគាត់ឈ្មោះ ហូរ ពិសីនោះ?

ខ៖ ហ្នឹងហើយគាត់ឈ្មោះហូរ ពិសី តែខ្ញុំអត់ដឹងទេថាគាត់កើតឆ្នាំណាទេ។

គ៖ តែប្រហែលជានៅក្នុងសំបុត្រកំណើតមាន។

ខ៖ ខ្ញុំមិនបានចាំអីពីម្តាយខ្ញុំ ទាំងអស់ហ្នឹងគ្រាន់តែខ្ញុំដឹងថាអាកន្លែងដែលខ្ញុំរស់នៅហ្នឹងគេហៅថាភូមិអូរបែកក្អម ហើយផ្ទះខ្ញុំហ្នឹងផ្ទះថ្មខ្ពស់ធំចាស់។

គ៖ ហើយអ្នកមីងមានអីចងចាំអីជាមួយនឹងយាយទេ?

ខ៖ ចងចាំមានតែចាំថាម្តាយខ្ញុំគាត់រស់នៅជាមួយខ្ញុំហ្នឹង គាត់លក់នំអន្សមណាចាសមានតែប៉ុណ្ណឹង ខ្ញុំនៅផ្ទះមើលប្អូនៗ។

គ៖ អញ្ចឹងអ្នកមីងដឹងទេថាគាត់ស្លាប់នៅពេលណា?

ខ៖ ម៉ាក់ខ្ញុំហ្នឹងគាត់គេជម្លៀសទៅ គាត់និងខ្ញុំក៏បែកគ្នាទៅនៅជំនាន់ប៉ុល ពតហ្នឹងជម្លៀសពីជំនាន់ប៉ុល ពតទៅអញ្ចឹងទៅប៉ាខ្ញុំទៅជាមួយប៉ាខ្ញុំ ហើយប៉ាខ្ញុំគាត់ក៏បែកជាមួយម្តាយខ្ញុំហើយគាត់បកមករកខ្ញុំវិញ។

គ៖ ហើយអត់ដឹងថាគាត់ស្លាប់ឬក៏រស់ទេ?

ខ៖ អត់ដឹងទេជំនាន់ហ្នឹងអត់ដឹងផង។

ក៖ អញ្ជឹងម៉ាក់ចាំពីជីតារបស់ម៉ាក់ទេ គាត់មានឈ្មោះអីដែរ?

ខ៖ ខ្ញុំអត់ចាំផងហ្នឹង ជីតា លោកយាយក៏អត់ចាំ។

ក៖ ចុះពីទីកន្លែងកំណើតគាត់អីណា?

ខ៖ ម៉ាក់អត់ចាំទាំងអស់ហ្នឹង។

គ៖ អញ្ជឹងចាំថាគាត់រស់ណាអត់មីង?

ខ៖ អត់ចាំសោះតែម្ដង ហើយអត់ទាំងស្គាល់មុខផងហ្នឹង។

គ៖ អញ្ជឹងមានដឹងអត់ថាឪពុកម្ដាយអ្នកមីងក៏ដូចជាតាយាយពីមុនមកតើគាត់ធ្លាប់មានទៅរស់នៅប្រទេសខាងក្រៅអត់?

ខ៖ អត់ខ្ញុំអត់ដឹងតែហ្មង។

ក៖ អញ្ជឹងម៉ាក់រៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ខ៖ និយាយទៅម៉ាក់រៀនបានត្រឹមថ្នាក់ទី២។

ក៖ អញ្ជឹងនៅសាលាបឋមសិក្សាឈ្មោះអីដែរម៉ាក់?

ខ៖ នៅសាលានេះក្រពើហាយើងនេះ។

ក៖ អញ្ជឹងតើក្ដីស្រម៉ៃម៉ាក់ទៅថ្ងៃអនាគតម៉ាក់ចង់ក្លាយទៅជាអ្វីដែរ?

គ៖ ដោយសារពេលមីងនៅពីក្មេងមីងតែងតែទៅរៀនហើយទៅរៀនអញ្ជឹងទៅតែងតែមានក្ដីស្រម៉ៃហើយតើមីងចង់ក្លាយទៅជាអ្វីដែរពេលធំឡើងអញ្ជឹងណាមីង?

ខ៖ អានេះនិយាយទៅគឺថាអញ្ជឹងពេលដែលខ្ញុំទៅរៀនអញ្ជឹងគឺខ្ញុំចង់ចេះ ចង់មើលអក្សរដាច់អី អញ្ជឹងណាប៉ុន្តែវាទៅអត់រួចហេតុអីបានជាខ្ញុំទៅមិនរួច ទី១ខ្ញុំរៀនអត់ចូលទី២បញ្ហារឿងសម្លៀកបំពាក់ ចាសហ្នឹងហើយគឺថាខ្ញុំមកនៅក្នុងវត្តហ្នឹងខ្ញុំឃើញគេមានសំពត់ខៀវអាសំពត់សិស្សសាលាយើងហ្នឹងមិនពណ៌ខៀវ ហើយនឹងអាអាវសហើយមិនអាក្រវ៉ាត់ករក្រហមអញ្ចេះនោះហើយចំណែកខ្ញុំស្លៀកស្បង់លោកទៅរៀនហ្នឹង លោកឱ្យក្រណាត់ស្ពោងជីវលោកកាត់សំពត់ឱ្យស្លៀកទៅរៀនហើយអាវខ្ញុំគេទេវែងអូសដល់ជង្គង់ទៀត។

កៈ អញ្ចឹងមកពីបញ្ហាការសិក្សានិងកាលហ្នឹងពេលម៉ាក់នៅរៀនម៉ាក់កម្សត់ខ្លាំងណាស់ម៉ាក់ហើយដោយសារលុយកាក់អីវ៉ាន់ចាយវាយមានតិចតួចដោយសារទើបតែបែកពីសង្គ្រាមផង។

ខៈ និយាយទៅអត់លុយចាយតែម្តងទៅរៀនមិនដែលមានលុយចាយទេហូបតែបាយទេហូបបាយនៅក្នុងវត្តលោក។

កៈ អញ្ចឹងម៉ាក់រៀបការនៅក្នុងថ្ងៃខែឆ្នាំណាដែរ?

ខៈ អត់ចាំផង។

កៈ អញ្ចឹងម៉ាក់មានចាំថាម៉ាក់រៀបការនៅរដូវប្រាំងឬក៏រដូវវស្សាដែរ?

ខៈ ការនៅកាលហ្នឹងរដូវវស្សារ។

គៈ ហើយកាលហ្នឹងការនៅពេលជំនាន់បែកប៉ុល ពតហើយឬក៏ម្តេចដែរ?

ខៈ បែកពីជំនាន់ប៉ុល ពតមកចូលមកនៅក្នុងវត្តក្រពើ ហារហ្នឹងតែហ្មង។

គៈ ហើយប្រហែលជាប៉ុន្មានឆ្នាំបានរៀបការ?

ខៈ ដល់ពេលខ្ញុំអាយុ១៨។

គៈ ប្រហែលជាបន្ទាប់ពីហ្នឹងប៉ុន្មានឆ្នាំដែរមីង ចាំទេ?

កៈ ចាសប្រហែលពេលដែលម៉ាក់បែកពីជំនាន់ប៉ុល ពតមកកាលហ្នឹងម៉ាក់អាយុប៉ុន្មាន?

ខៈ ឥឡូវមីអូនឯងជួយគិតខ្ញុំទៅឆ្នាំ៧៥ខ្ញុំអាយុ៥ឆ្នាំ គិតទៅចូលទៅអាពតទៅបែកអាពតមកវិញ។

គៈ អូ...អញ្ចឹងមីងប្រហែលជារៀបការនៅឆ្នាំ១៩៨៨?

កៈ អត់ទេខ្ញុំ១៩៨៨ ខ្ញុំកើតហើយហ្នឹង អត់ទេៗ។

ខៈ អត់ទេឆ្នាំ១៩៨៧រតនាកើតហើយហ្នឹង ហើយខ្ញុំអាយុ២១បានកូនមួយហ្នឹង អាយុ២១បានរតនាមួយ។

គ ៖ ហើយការហើយភ្លាមមានកូនភ្លាមទេ?

ខៈ អត់ទេខ្ញុំទំនេរពោះ៣ឆ្នាំណោះ។

គៈ អញ្ចឹងមីងរៀបការនៅឆ្នាំ១៩៨៤ហ្នឹងហើយ។

កៈ ចាសហើយកន្លែងដែលម៉ាក់ការហ្នឹងនៅណាវិញ?

ខៈ នៅក្រពើហារនេះនៅខាងត្បូងវត្តនេះ ជាកន្លែងដែលខ្ញុំរស់នៅៗជិតវត្តហ្នឹងតែហ្មង។

គៈ ចាស!

កៈ ហើយពេលដែលម៉ាក់រៀបការហ្នឹងឪពុកម្ដាយជាអ្នករៀបចំឱ្យឬក៏ម៉ាក់ស្រលាញ់ប៉ាដោយខ្លួនឯង?

ខៈ ឪពុកម្ដាយជាអ្នករៀបចំឱ្យ។

កៈ ហើយកាលហ្នឹងអត់មានចិត្តស្រលាញ់ប៉ាអីបន្តិចតែហ្មងហោ?

ខ ៖ អត់ទេគាត់ជាអ្នករៀបចំឱ្យ។

កៈ ហើយម៉ាក់ជួបប៉ាលើកដំបូងនៅណាដែរហើយពេលណាដែរ?

ខៈ ជួបពេលគាត់មកផ្ទះខ្ញុំតែហ្មង គាត់មកហូបបាយផ្ទះខ្ញុំ។

កៈ អញ្ចឹងពេលដែលគាត់មកទិញបាយម៉ាក់ណោះ?

ខៈ ហ្នឹងហើយកាលហ្នឹងខ្ញុំលក់បាយ។

កៈ អញ្ចឹងកាលហ្នឹងម៉ាក់លក់ដូរ លក់អីខ្លះទៅម៉ាក់?

ខៈ លក់បាយ។

កៈ លក់តែបាយហ្នឹងឯ

ខៈ លក់សម្លរហ្នឹង។

កៈ អញ្ចឹងបែបឆ្ងាញ់ហើយមើលទៅបានជាប៉ាមកញ៉ាំ អ្នកលក់ស្អាតហើយម្ហូបឆ្ងាញ់ទៀត។ ហើយម៉ាក់រៀបការហ្នឹងមានបណ្ដាការទេ?

ខៈ បណ្ដាការមានហៃរជំនូន ហូប១៥តុ។

កៈ ហូ ...កាលជំនាន់ហ្នឹងហូប១៥តុមិនធម្មតាទេណា

ខៈ ហើយការមួយយប់មួយថ្ងៃ។

កៈ អូ! ហើយការសុទ្ធតែមួយយប់មួយថ្ងៃទៀត! ហើយមានអកកេះទេម៉ាក់?

ខ៖ អូ... លេងឡើងទល់ភ្លឺ។

គ៖ អូ... អញ្ចឹងកាលជំនាន់ហ្នឹងមានណាស់ អញ្ចឹងសប្បាយដល់ហើយនៀក ។

ក៖ សប្បាយមែនទេហ្មងម៉ាក់ អញ្ចឹងជីវិតរបស់ម៉ាក់នៅអតីតកាលនិងបច្ចុប្បន្នកាលតើមានភាពខុសគ្នាម្តេចខ្លះដែរម៉ាក់? នៅពេលពីមុនមក ហើយនិងពេលឥឡូវ ខុសគ្នាម្តេចដែរ?

គ៖ ស្រួលម្តេច ពិបាកម្តេច សប្បាយម្តេច អញ្ចឹងណា?

ខ៖ កាលពីមុនពេលយើងមានប្តីមានកូនហ្នឹងណោះ?

គ៖ ហ្នឹងហើយ។

ខ៖ គឺថាវាសប្បាយខ្លះវាកើតទុក្ខខ្លះអញ្ចឹងទៅណា ហើយដល់ពេលយើងមានកូនមានចៅវាក៏ធម្មតាអញ្ចឹងទៅ ដល់ពេលមកឥឡូវក៏ធម្មតាអញ្ចឹងដែរទៅមានសប្បាយខ្លះ ហើយក៏មានកើតទុក្ខខ្លះដែរហ្នឹង។

ក៖ ហើយម៉ាក់ឯងមាននឹកប៉ាអីទេ?

ខ៖ គាត់ស្លាប់ហើយ។

គ ៖ មាននឹកគាត់ខ្លះទេ?

ខ៖ នឹកដែរ។

ក៖ ហើយម៉ាក់ឯងចូលចិត្តម្ហូបអីជាងគេ?

ខ៖ ម្ហូបអត់មានរើសមុខទេស្អីក៏ហូបបានដែរ។

គ៖ ប៉ុន្តែម្ហូបអីដែរឆ្ងាញ់ជាងគេណា?

ក៖ អ្វីដែលម៉ាក់ចូលចិត្តពិសារជាងគេហ្នឹងណា ហើយម៉ាក់ថាឆ្ងាញ់ជាងគេ?

ខ៖ និយាយទៅតាំងពីខ្ញុំនៅតូចរហូតដល់មកដល់ធំគឺថាស្អីក៏ហូបបានដែរហើយអត់មានដឹងថាមុខអីដែលថាមិនចូលចិត្ត។

ក៖ តែបើតាមតែខ្ញុំចំណាំមើលម្ហូបដែលម៉ាក់ហូបបាយបានច្រើនជាងគេ គឺប្រហុកចិញ្ច្រាំ។ ត្រូវអី? ហូបអស់បាយនឹងធ្វើ។ ម៉ាក់ហូបបានច្រើន។ ហើយម៉ាក់ចេះធ្វើម្ហូបអត់?

ខ៖ ចេះ។

ក៖ ខ្ញុំឃើញម៉ាក់ខ្ញុំធ្វើរាល់ថ្ងៃ? ហើយម៉ាក់ចេះធ្វើម្ហូបហ្នឹងមកពីណាដែរ?

ខ៖ ចេះធ្វើម្ហូបមកពីយាយ។

ក៖ យាយជាអ្នកបង្រៀន។ អញ្ចឹង ម៉ាក់ចេះធ្វើម្ហូបច្រើនណាស់។ ខ្ញុំដឹងថាម៉ាក់ខ្ញុំស្លរឆ្ងាញ់គាត់ចេះធ្វើម្ហូបឆ្ងាញ់ៗណាស់ ហើយតើពេលទំនេរម៉ាក់ចូលចិត្តធ្វើអីដែរ?

ខ៖ និយាយពីពេលទំនេរដូចជាអត់ទំនេរទេ អត់មានពេលណាទំនេរបើការងារផ្ទះងាកទៅឃើញតែកន្លែងធ្វើរហូតហ្នឹង អត់មានទំនេរទេបើថាយើងឆ្លៀតពេលទំនេរយើងបានអង្គុយលេងខ្លះអីអញ្ចឹងអីទៅណាហើយបើថាឱ្យទំនេរដូចជាអត់ទេ។

ក៖ ហើយម៉ាក់ចូលចិត្តទៅដើរលេងនៅកន្លែងណាដែរម៉ាក់?

ខ៖ បើដើរលេងមានតែទៅមាត់ទន្លេលំហែរកាយអញ្ចឹង។

ក៖ ម៉ាក់ភាគច្រើនចូលចិត្តទេសភាពឬក៏ចូលចិត្តទឹកសមុទ្រអីអញ្ចឹងហ្នឹងណា?

ខ៖ ទឹកសមុទ្រទៅវាមិនដល់ទេព្រោះអីយើងវាអត់លុយ។ [សើច]

ក៖ ទោះបីជាទៅមិនដល់ក៏យើងមានក្តីស្រម៉ៃដែរថាចង់ទៅកន្លែងណាដែរ?

ខ៖ ចង់ទៅសមុទ្រវាម ចង់ទៅសមុទ្រចង់ទៅស្អីគេហៅទឹកជ្រោះអីនោះព្រោះមិនដែលបានទៅទេ។

ក៖ អូ...ហ្នឹងជាក្តីស្រម៉ៃរបស់ម៉ាក់ហើយហ្នឹងណាគឺជាទឹកសមុទ្រនិងទេសភាពតាមដងភ្នំអីអញ្ចឹងទៅណោះ ទឹកជ្រោះអីអញ្ចឹងអីទៅណោះម៉ាក់។ អញ្ចឹងម៉ាក់ចូលចិត្តលេងល្បែងប្រជាប្រិយអីដែរនៅពេលចូលឆ្នាំម្តងៗអញ្ចឹងណា?

ខ៖ ពេលចូលឆ្នាំខ្ញុំចូលចិត្តច្រៀងបោះឈូង។

ក៖ អូ...អាហ្នឹងល្បែងបោះឈូង អាហ្នឹងគេហៅថាល្បែងបោះឈូងអញ្ចឹងល្អមែនទែនណោះហើយនៅមានល្បែងអីក្រៅពីហ្នឹងទៀតទេដែលម៉ាក់ចូលចិត្ត?

ខ៖ បោះអង្គុញអញ្ចឹងទៅ តែបោះអង្គុញវាមិនសូវសប្បាយទេគេយកមកគោះជើងវាឈឺ ហើយចូលចិត្តរាំ។

ក៖ ចាសចូលចិត្តរាំ ដៃម៉ាក់ទន់ណាស់ ហាីអឺ...អញ្ចឹងតែម៉ាក់ចូលចិត្តចម្រៀងបែបណាដែរដូចជាបទមនោសញ្ចេតនាឬក៏បទញាក់ៗបទប្រជាប្រិយណា?

ខ៖ និយាយទៅបទចម្រៀងបទមនោសញ្ចេតនានោះក៏ចូលចិត្ត អាបទចម្រៀងញាក់ៗហ្នឹងបើយើងយកមកហាត់ប្រាណនោះក៏វាចូលចិត្ត។

ក៖ ចូលចិត្តបទញាក់ៗយកមកហាត់ប្រាណ អញ្ចឹងសូមម៉ាក់ជួយប្រាប់ខ្ញុំពីជំនាន់ដែលម៉ាក់រស់នៅហ្នឹងណា កាលពីជំនាន់ប៉ុល ពតហ្នឹងតើម៉ាក់ជួបការលំបាកអីខ្លះនៅពេលហ្នឹងណាម៉ាក់នៅពេលហ្នឹងជីវិតរបស់ម៉ាក់យ៉ាងម្ដេចដែរទៅ?

ខ៖ ចាសដែលខ្ញុំនៅកាលជំនាន់ប៉ុល ពតហ្នឹងខ្ញុំនៅក្នុងអង្គភាពកុមារនិយាយទៅមុននឹងវាប្រើយើងឱ្យធ្វើការឱ្យវាហ្នឹងរែកអាចម៍គោហ្នឹង គឺវាឱ្យយើងទៅហូបបបរវាដាំបបរ បបររាវៗក្នុងមួយចានហ្នឹងវាមានតែគ្រាប់អង្ករហ្នឹងតែពីរ បីគ្រាប់ទេហើយបបរ បបរអង្ករដុបៗទៀតអត់រីកទេណា។ចាស បើយើងប្រមូលមកក្នុងមួយចានហ្នឹងមានប្រហែលជាតែមួយស្លាបព្រាទេគ្រាប់អង្ករមួយកូនចានយើងអាតូចហ្នឹង ហើយក្នុងមួយវង់ហ្នឹងវាមាន១០នាក់ ហើយដាក់អំបិលនៅកណ្ដាលហើយដល់ពេលហើយទៅគេហៅថាកូនមូលដ្ឋានហ្នឹងវាឃើញខ្ញុំវាអាណិតនោះ ឃើញអាណិតវាអត់ចង់ឱ្យខ្ញុំហ្នឹងហូបបបរហ្នឹងទេ វានាំទៅផ្ទះវា គាត់នាំខ្ញុំទៅផ្ទះគាត់ទៅដូសបាយបាយឱ្យហូប គាប់ជូនអីម្ដាយគាត់ក៏មកទាន់អញ្ចឹងទៅម្ដាយគាត់ថាអឺ..កូនឯងម្ដេចក៏ឱ្យបាយគាត់ហូបអញ្ចឹងប្រយ័ត្នគេដឹងគេយកទៅសម្លាប់ចោលណា ហីដល់ពេលហើយគ្រាន់តែខ្ញុំដើរចេញទៅអញ្ចឹងស្រាប់តែអឺ...ប្រធានគេដឹងណាប្រធានគេដឹងអញ្ចឹងគេយកខ្ញុំទៅវាយ។

គ៖ ហើយវាយទៅម្ដេចទៅអញ្ចឹងមីង?

ខ៖ គេវាយខ្ញុំខ្លាំងណាស់គេវាយសុទ្ធតែអុកក្បាលខ្ញុំ។

ក៖ ពូកអាពតហ្នឹងសាហាវណាស់ណា នៅពេលហ្នឹងហូបចុកអីក៏តឹងរឹងតាមតែខ្ញុំស្ដាប់ម៉ាក់ទៅខ្ញុំពិតជាមានអារម្មណ៍អាណិតម៉ាក់មែនទែន ហី ក៏ជំនាន់ហ្នឹងវាពិតជាពិបាក គិតថានៅពេលដែលម៉ាក់នៅជំនាន់ហ្នឹងប្រសិនបើជាខ្ញុំនៅក្នុងព្រឹត្តិការណ៍ហ្នឹងវិញណាខ្ញុំនឹងមានអារម្មណ៍កាន់តែពិបាកខ្លាំណាស់ជាងម៉ាក់ទៀតណោះ ខ្ញុំទឹកភ្នែករាល់ថ្ងៃហើយមើលទៅ។

ខ៖ ហើយកាលជំនាន់ហ្នឹងគ្មានអីទេ បន្ទាប់ពីហូបបបរហ្នឹងហើយណាអត់មានអីហូបទៀតទេហើយអង្ករនៅក្នុងផ្ទះខ្ញុំហ្នឹងណាក៏អត់មានដែរ ហើយខ្ញុំក៏ទៅរើសគួរស្រូវ ដល់ពេលទៅរើសគួរស្រូវហើយគេច្រូតដល់មុខអញ្ចឹងបានយើងទៅរើសតាមក្រោយ ដល់ពេលហើយអាប្រធានកងគេឃើញនោះហើយរើសក៏មានមែន រើសទាំងខ្ញុំដែរ រើសឡើងបួនប្រាំនាក់ណោះ ដល់ពេលហើយប្រធានកងវាឃើញវាក៏ហៅទៅហើយវាក៏សួរថាម្ដេចបានដើររើសគួរស្រូវអញ្ចឹង ខ្ញុំក៏ថាមកពីផ្ទះខ្ញុំអត់អង្ករហូបទេបានខ្ញុំរើសគួរស្រូវ ហើយវាថាថ្ងៃក្រោយទោះបីជាឃើញគួរស្រូវ

យ៉ាងណាក៏ដោយក៏កុំរើសគួរស្រួវណានិយាយអញ្ចឹងហើយវាដើរវាយហើយវាចាប់ដូចគ្នា២នាក់អង្គុយអញ្ចឹងណាវាចាប់ក្បាលអុកចូលគ្នា អុកមាំងៗហ្មងណាឡើងជាំ។

កៈ អញ្ចឹងហើយឥឡូវនៅពេលក្នុងជំនាន់ប៉ុល ពត ម៉ាក់មានបានជួបបងប្អូនរបស់ម៉ាក់អីខ្លះទេ?

ខៈ អត់ទេ អត់មានបានជួបផង។

គៈ អញ្ចឹងបែកគ្នារហូតតែហ្មង?

ខៈ ចាសបែកទាំងអស់។

កៈ ហើយបន្ទាប់ពីរបបពុលពតមកតើម៉ាក់ប្រកបរបរចិញ្ចឹមជីវិតអីដែរ?

គៈ បន្ទាប់ពីជំនាន់ហ្នឹងបែកហើយណាអ្នកមីង?

ខៈ បែកជំនាន់ប៉ុល ពតហើយណោះ ខ្ញុំចូលមកវិញពីនោក់ម្ដាយចិញ្ចឹមខ្ញុំគាត់យកវត្តធ្វើផ្ទះតែហ្មង ហើយខ្ញុំក៏ចេះតែរស់នៅក្នុងវត្តបម្រើលោកអញ្ចឹងទៅ ដល់ពេលខ្ញុំរាងធំបន្តិចទៅបានលោកឱ្យខ្ញុំចូលរៀននៅសាលា តែខ្ញុំចូលរៀននៅសាលាខ្ញុំអត់មានអីស្លៀកទេនិយាយទៅលោកតាខ្ញុំគាត់ក៏អត់ឱ្យលុយខ្ញុំទៅទិញសម្លៀកបំពាក់ទោះបីជាម្ដាយខ្ញុំមានលុយហើយគាត់នាំខ្ញុំទៅផ្សារគាត់តថ្លៃជាមួយគេហើយថ្លៃបន្តិចក៏គាត់អត់យកដែរ ខ្ញុំឃើញគាត់តជាមួយគេម៉ាត់ប្រៃហើយអត់ព្រមយកអាក្រណាត់ហ្នឹងមកកាត់សំពត់ឱ្យខ្ញុំទេ ខ្ញុំក៏មានចិត្តដើរចេញទៅព្រោះម៉ែខ្ញុំគាត់តគេហើយគាត់អត់យកដូចជាគាត់មិនចង់ទិញឱ្យខ្ញុំស្លៀកទេណា។

កៈ ហឺ...អញ្ចឹងម៉ាក់ នៅក្នុងជីវិតរបស់ម៉ាក់ចងចាំអ្វីជាងគេ?

គៈ អ្វីដែលចងចាំជាងគេនៅក្នុងជីវិតរបស់មីងណា?

ខៈ និយាយទៅចងចាំជាងគេគឺអារឿងកម្សត់ៗតែហ្មង បែកឪពុកម្ដាយអស់អង្គុយតែយំកម្សត់ហ្មងខ្ញុំនឹកឃើញថាបើឪពុកម្ដាយខ្ញុំនៅទាំងអស់ក៏ខ្ញុំរៀនបានច្រើនដែរចាស។

កៈ ចាសអញ្ចឹងក្រោយពីរៀបការហើយតើម៉ាក់មានកូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខៈ តាំងពីរៀបការមកមានខ្ញុំមានកូន៥នាក់។

កៈ ចាសហើយឈ្មោះអ្វីខ្លះដែរ?

ខៈ ទី១ឈ្មោះ ម៉ៅ រតនា ទី២ឈ្មោះ ម៉ៅ រដ្ឋា ទី៣ឈ្មោះ ម៉ៅ រ៉ូហ្សា ទី៥ឈ្មោះ ម៉ៅ រ៉ាន់យ៉ា។

កៈ អញ្ចឹងម៉ាក់មានកូនចិញ្ចឹមអត់?

ខ៖ កូនចិញ្ចឹមអត់មានទេ។

ក៖ ហើយប៉ាឈ្មោះអីដែរ?

ខ៖ ឈ្មោះ ម៉ៅ សុខា។

ក៖ តើប៉ាគាត់មានអត្តចរិកម្តេចដែរ?

ខ៖ គាត់មានអត្តចរិកស្លូតបូត គាត់ស្រលាញ់ប្រពន្ធនិងកូនគាត់ជាមនុស្សម្នាក់ដែលមានជំហររឹងមាំគាត់ជាមនុស្សដែលស្រលាញ់ប្រពន្ធកូន។

ក៖ ខ្ញុំក៏មើលឃើញអញ្ចឹងដែរ គាត់ពិតជាស្រលាញ់ម៉ាក់និងស្រលាញ់ពួកខ្ញុំខ្លាំងមែនទែន។

ហើយឥឡូវហ្នឹងម៉ាក់ប្រកបរបរអីដែរ?

ខ៖ ពីមុនគឺខ្ញុំធ្វើការសន្តិសុខ តែឥឡូវនេះដូចថាមានជម្ងឺទឹកនោមផ្អែម ខ្ញុំទ្រុនទ្រាណាស់ឥឡូវខ្ញុំធ្វើអីអត់កើតទេខ្ញុំនៅស្ងៀមនៅមើលជម្ងឺខ្ញុំណា ក្នុងមួយខែ២០រៀល។

ក៖ ហើយតើរបៀបដែលម៉ាក់ចិញ្ចឹមកូនៗនិងអប់រំកូនៗដោយរបៀបណា?

ខ៖ ខ្ញុំចិញ្ចឹមកូនៗឱ្យកូនហូបជាការធម្មតាឱ្យបានគ្រប់គ្រាន់មើលថែកូនអញ្ចឹងទៅឱ្យកូនមានសុខភាពល្អអញ្ចឹងទៅគ្រាន់តែថាខ្ញុំចិញ្ចឹមកូនដោយធម្មតាហ្នឹង ពីរនាក់ប្តីប្រពន្ធក៏នៅតែខ្វះខាតអញ្ចឹងដែរណាស់តែបានម្តាយខ្ញុំគាត់ជួយផ្ទុងផ្តើមឱ្យលុយកូនខ្ញុំចាយទៅរៀនអីអញ្ចឹងទៅព្រោះប្តីខ្ញុំគាត់ឈឺដែរគាត់ឈឺសន្លាក់ដៃ សន្លាក់ជើង ឈឺក្រពះ។

ក៖ ហើយម៉ាក់មានបានឱ្យកូនៗហ្នឹងទៅរៀនអត់?

ខ៖ ឱ្យៗទៅរៀន។

ក៖ ហេតុអីបានជាម៉ាក់ឱ្យកូនទៅរៀន?

ខ៖ ព្រោះចង់ឱ្យកូនចេះ។

ក៖ តើតម្លៃនៃការអប់រំហ្នឹងមានតម្លៃយ៉ាងណាចំពោះម៉ាក់?ខ្ញុំចង់និយាយថាតម្លៃដែលម៉ាក់បានឱ្យពួកខ្ញុំទៅរៀនហ្នឹងណា តើវាមានអត្ថន័យយ៉ាងណាចំពោះម៉ាក់ដែរបានជាម៉ាក់ឱ្យពួកខ្ញុំទៅរៀន  អញ្ចឹងហ្នឹងណា?

ខ៖ សួរខ្ញុំអញ្ចឹងខ្ញុំអត់ចេះឆ្លើយទេ បើថាឱ្យទៅរៀនដើម្បីឱ្យកូនចេះដឹងណាស់ទៅថ្ងៃមុខទៅឱ្យកូនខំប្រឹងរៀន កូនចេះទៅកូនរកការងារធ្វើ ចាសហើយកូនមានការងារធ្វើក៏ងាយស្រួលនឹង

ចិញ្ចឹមជីវិតខ្លួនឯង ចាសពេលដែលម្ដាយចាស់ទៅម្ដាយក៏មានសង្ឃឹមលើកូនៗដែរអញ្ចឹងបើខ្ញុំនិយាយអញ្ចឹងខ្ញុំនិយាយបាន។

ក៖ ចាសហើយត្រូវធ្វើដូចម្ដេចដើម្បីឱ្យគ្រួសារម៉ាក់មានសុភមង្គលបានម៉ាក់អាចចែកចាយបន្តិចបានទេ?

ខ៖ ក្រុមគ្រួសារមានសុភមង្គលបានរស់នៅជាមួយគ្នា មានតែការសេចក្ដីស្រលាញ់ហើយចេះណែនាំ ហើយចេះអត់ធ្មត់ មានមេត្តា ករុណា។

ក៖ ខ្ញុំឃើញមកនៅក្នុងគ្រួសារអញ្ចឹងមែនម៉ាក់តែងតែមានសេចក្ដីមេត្តាករុណា មានសេចក្ដីស្រលាញ់ចំពោះកូនៗពិតប្រាកដមែន ហើយលោកប៉ាក៏គាត់ស្រលាញ់ក្រុមគ្រួសារ គាត់មានមេត្តាករុណាដូចគ្នានិងសេចក្ដីស្រលាញ់ខ្លាំងធំ ចំពោះម៉ាក់ហើយនិងខ្ញុំ។

គ៖ អញ្ចឹងអ្នកមីងដូចជាប្ដីអ្នកមីងណាតើគាត់ស្លាប់ឬក៏រស់ដែរ?

ខ៖ គាត់ស្លាប់ហើយ។

គ៖ ស្លាប់នៅឆ្នាំណាដែរ?

ខ៖ គាត់ស្លាប់ដូចជាបាន៥ឆ្នាំហើយ។

គ៖ ២០០០ប៉ុន្មានដែរ?

ខ៖ និយាយទៅគាត់ស្លាប់នៅក្នុងឆ្នាំ២០១២ ទៅ២០១៣ហ្នឹងខ្ទង់ឆ្នាំហ្នឹង។

ក៖ ហើយតើម៉ាក់ធ្វើដូចម្ដេចដើម្បីឱ្យគ្រួសាររបស់ម៉ាក់មានសុភមង្គល?ហើយពេលដែលក្រុមគ្រួសារមានបញ្ហា តើម៉ាក់មានវិធីសាស្រ្តបែបណាដែរដើម្បីដោះស្រាយ?

ខ៖ វិធីដោះស្រាយមានតែការពិភាក្សា ហើយនិងការពិភាក្សាដោយគ្មានអំពើហឹង្សាទេអញ្ចឹងបានយើងដោះស្រាយចេញ មានការពិភាក្សាហើយ ធម្មតាការនិយាយវាតែងតែមានខឹងនិងមានអត់ខឹងហើយណា ហើយតែកាលណាខឹងយើងជជែកគ្នាខ្លាំងហើយចាសមានតែការពិភាក្សាហ្នឹងទេដែលល្អ អញ្ចឹងមានតែយើងពិភាក្សាគ្នាទៅបានយើងមានសុភមង្គល។

ក៖ អញ្ចឹងពេលកន្លងមកខ្ញុំពិតជាបានធ្វើអញ្ចឹងមែនព្រោះម៉ាក់តែងតែនាំពួកខ្ញុំពិភាក្សាដើម្បីរកដំណោះស្រាយបានល្អមែន។ហើយអញ្ចឹងតើគ្រួសារមានអត្ថន័យយ៉ាងណាចំពោះម៉ាក់ ដូចជាម៉ាក់ចាប់ផ្ដើមរៀបការហើយបន្ទាប់មកក៏មានប្ដីមានកូនៗ អញ្ចឹងម៉ាក់មានអារម្មណ៍យ៉ាងណាដែរពេលដែលម៉ាក់មានប្ដីនិងមានកូនហ្នឹងណា ថាមានអត្ថន័យអ្វី?

ខ៖ ពេលដែលមានប្តីមានកូនទៅនេះយើងមានគ្រួសារធំមួយមានភាពរីករាយនៅក្នុងគ្រួសារបានល្អចេះអប់រំគ្នាទៅវិញទៅមកនិងមានសុភមង្គលនៅក្នុងគ្រួសារ។

ក៖ អញ្ចឹងតើម៉ាក់មានបទពិសោធន៍អីល្អខ្លះៗក្នុងជីវិតរបស់ម៉ាក់សម្រាប់ទុកចែករំលែកមកឱ្យខ្ញុំទេនិងទៅកាន់កូនចៅជំនាន់ក្រោយដែរឬទេ?

ខ៖ ខ្ញុំមានបទពិសោធន៍ដូចថាកាលដែលយើងនៅម្នាក់ឯងអញ្ចឹងហ្នឹងណា យើងនៅម្នាក់ឯងយើងធ្វើអ្វីយើងធ្វើឱ្យរហ័សរហួន ឧទាហរណ៍ថាយើងនៅក្នុងផ្ទះអញ្ចឹងយើងមើលចានមើលឆ្នាំងមើលបោសសម្អាតផ្ទះអញ្ចឹងទៅ ណាបោកខោអាវអញ្ចឹងទៅមើលបន្ទប់គេងអីគេបទភួយបទមុង ឲ្យស្អាតអញ្ចឹងទៅ។

ក៖ សំហើយណួរចុងក្រោយ តើម៉ាក់មានដំបូលន្មានអីចង់ផ្តាំផ្ញើរទៅកាន់ក្មេងៗជំនាន់ក្រោយដូចជាម៉ាក់ចង់ទូន្មានប្រដៅអីសម្រាប់កូនចៅជំនាន់ក្រោយខ្លះដែរ?

ខ៖ ចង់ទូន្មានកូនចៅជំនាន់ក្រោយសូមឱ្យកូនចៅហ្នឹងចេះស្តាប់បង្គាប់ឪពុកម្តាយនៅពេលដែលប្រដៅ ទូន្មានអញ្ចឹងហ្នឹងណា ឱ្យខិតខំរៀនសូត្រអញ្ចឹងទៅ។ ហើយនិងយកចិត្តទុកដាក់ទៅ ហើយខំប្រឹងធ្វើការងារផ្ទះខាងក្នុងនិងខាងក្រៅអីឱ្យស្អាតនិងឱ្យ រហ័សដៃរហ័សជើងអញ្ចឹងទៅ។

ក៖ ចាស ហើយខ្ញុំសូមថ្លែងអំណរគុណសម្រាប់ការសម្ភាសនៅក្នុងថ្ងៃនេះ។ អ្វីៗទាំងអស់នេះកូនចៅរបស់អ្នកម៉ាក់កាន់តែដឹងលឺនិងប្រវត្តិរបស់ម៉ាក់។ ហើយពួកយើងនឹងដាក់ចូលការសម្ភាសនេះទៅក្នុងវេបសាយខាងលើ។ សូមអរគុណម៉ាក់៕

គ៖ អរគុណច្រើន!